# អត្ថបទរបាំម៉ុងសាយក្នុងពិធីចូលឆ្នាំប្រពៃណីចិន

ជារៀងរាល់ឆ្នាំ នៅពេលដែលមានពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន ប្រជាជនចិន និង ប្រជាជនខ្មែរជាប់សែស្រឡាយចិន តែងតែប្រារព្ធពិធីចូលឆ្នាំថ្មី ចំណែកឯប្រជាជននៅក្រៅប្រទេសវិញ បានហៅពិធីបុណ្យនេះថា៖ «**បុណ្យចូលឆ្នាំ ច័ន្ទគតិថ្មី**» ពិធីបុណ្យនេះបានចាប់ផ្តើមនៅថ្ងៃទីមួយ នៃខែទីមួយ តាមច័ន្ទគតិ ក្នុងប្រតិទិនចិន ហើយបញ្ចប់ទៅវិញនៅថ្ងៃទី១៥ ដែលគេហៅថ្ងៃនេះថា៖ **ពិធីបុណ្យបង្ហោះគោម**។ បុណ្យចូលឆ្នាំចិន ស្ថិតក្នុងថ្ងៃខុសៗគ្នានៅរៀងរាល់ឆ្នាំ គឺនៅចន្លោះថ្ងៃទី២១ ខែមករា ដល់ ថ្ងៃទី២០ ខែកុម្ភៈ។ នៅក្នុងថ្ងៃដែលប្រារព្ធពិធីបុណ្យនេះ គេតែងតែឃើញមាននូវ "**របាំម៉ុងសាយ**" និង ការដុតផាវជាប្រចាំ។ "**របាំម៉ុងសាយ**" ឬ "**របាំសត្វតោ**" គឺជាការសម្តែងក្បាច់រាំបែបប្រពៃណីចិន នៅក្នុងឱកាសពិសេសធំៗ មាន ពិធីបុណ្យចូលឆ្នាំចិនជាដើម ដើម្បីនាំមកនូវសំណាងល្អ ព្រោះគេជឿជាក់ថា តោជាសត្វដ៏វិសេសវិសាល។ តើហេតុអ្វីបានជាមានរបាំនេះក្នុងថ្ងៃប្រារព្ធពិធីបុណ្យចូលឆ្នាំនេះ?

## I. ប្រវត្តិដើមនៃរបាំម៉ុងសាយ



សត្វតោតំណាងឱ្យម៉ុងសាយ

ប្រភពដើមនៃរបាំសត្វតោ ឬ ម៉ុងសាយ នេះ ត្រូវបែងចែកយ៉ាងទូលំលាយ ប៉ុន្តែមតិដែលគួរឱ្យទុកចិត្តបំផុតមួយគឺ៖ នៅក្នុងវប្បធម៌ប្រពៃណីចិន សត្វតោ ប្រៀបបានដូចជាសត្វនាគអីចឹង គឺជាសត្វដែលកើតមានតែនៅក្នុងទេវកថាប៉ុណ្ណោះពេលគឺគ្មានសត្វតោពិតប្រាកដ នៅក្នុងប្រទេសចិនឡើយ។ នៅមុនសម័យរាជវង្សហាន (ឆ្នាំ២០២ មុនគ្រិស្តសករាជ ដល់ ២២០ ក្រោយគ្រិស្តសករាជ) មានសត្វតោតែប៉ុន្មានក្បាលប៉ុណ្ណោះ ដែលបានមកដល់តំបន់ភាគខាងលិច នៃប្រទេសចិនបុរាណ (បច្ចុប្បន្នគឺជាទីក្រុង Xinjiang) ដោយសារតែការធ្វើជំនួញសូត្រ។ នៅពេលនោះ មនុស្សបាននាំគ្នាធ្វើត្រាប់តាមរូបរាង និងសកម្មភាពនៃសត្វតោ ដែលទើបតែមកដល់ថ្មីៗ នៅក្នុងការសម្តែងរហូតបង្កើតបានទៅជារបាំសត្វតោនៅក្នុងសម័យកាលនគរទាំង៣ (ឆ្នាំ២២០ ដល់ ២៨០)។ ក្រោយមកវាបានក្លាយជាការពេញនិយម នៅក្នុងសម័យរាជវង្សខាងជើង និង ខាងត្បូង(ឆ្នាំ ៤២០ ដល់ ៥៨៩)។ រហូតដល់សម័យរាជវង្សថាង (ឆ្នាំ ៦១៨ ដល់ ៩០៧) របាំសត្វតោបានក្លាយជារបាំមួយនៅក្នុងសាលរាំ។ បន្ទាប់មក របាំសត្វតោ នេះបានក្លាយជាការសម្តែងដ៏ពេញនិយមនៅក្នុងចំណោមប្រជាជនចិន ដើម្បីអធិដ្ឋានសុំសំណាងល្អ ក្នុងអំឡុងពិធីបុណ្យចូលឆ្នាំចិន និងឱកាសពិសេសដទៃជាច្រើនទៀត។[1]

[1] តើម៉ុងសាយមានដើមកំណើតដំបូងមកពីណា? https://kleykley.sabay.com.kh/article/1186205 (accessed January 01, 2022, at 2:30 pm)

ប៉ុន្តែរបាំសត្វតោនេះ ក៏មានរឿងតំណាលផ្សេងៗមួយចំនួនទៀត ដោយលើកឡើងខុសគ្នាថា កាលពីព្រេងនាយមានរឿងមួយតំណាលថា មានព្រះសង្ឃមួយអង្គបានសុបិនឃើញថា មានទុក្ខវេទនា និងបិសាច ជាច្រើនបំផ្លាញពិភពលោក។ ព្រះសង្ឃនោះបានបន់ស្រន់ និងសួរទៅព្រះពុទ្ធថា៖ តើត្រូវធ្វើដូចម្តេច ដើម្បីការពារមិនឱ្យមានពួកបិសាចទាំងអស់នោះ? ព្រះពុទ្ធមានបន្ទូលទៅកាន់ព្រះសង្ឃអង្គនោះថា សិង្ហ (ម៉ុងសាយ) អាចការពារ និង ប្រយុទ្ធនឹងបិសាចទាំងអស់នោះបាន។ ប្រជាជនចិនមិនធ្លាប់ឃើញសិង្ហពីមុនឡើយ ប៉ុន្តែធ្លាប់ឮរឿងដំណាលៗគ្នាថា៖ សិង្ហ គឺជាស្តេចលើសត្វទាំងអស់។ ដូច្នេះព្រះអង្គបានបញ្ចូលតួអង្គសត្វមានសំណាង ឬ សត្វទេវកថាទាំងអស់ ហើយបន្ទាប់មកបង្កើតជាម៉ុងសាយនេះ។

ចំណែក អ្នកខ្លះទៀតដំណាលថា កាលពីរាប់រយឆ្នាំមុន មានភូមិតូចមួយនៅចិន ត្រូវគំរាមកំហែងនៅថ្ងៃចូលឆ្នាំថ្មី ដោយក្រុមចោរព្រៃ ដែលតែងខ្លួនជាសត្វព្រៃចម្លែកៗ។ ក្រុមចោរនេះ បានបន្លាចប្រជាជនឱ្យរត់ចេញពីលំនៅដ្ឋាន អាលនឹងលួចរបស់របរក្នុងផ្ទះ និងដីស្រែរបស់ពួកគេ។ ដោយសារភាពអត់ឃ្លានអ្នកភូមិក៏ងើបឈរប្រឆាំងនឹងក្រុមចោរព្រៃមិនស្គាល់មុខនោះនិងបានបង្កើតសំលៀកបំពាក់ក្លែងក្លាយមួយដែលឈ្មោះថាម៉ុងសាយ តំណាងឱ្យ(សិង្ហឬតោ)។ សំលៀកបំពាក់នោះធ្វើពីគ្រោងឫស្សី ស្រោបដោយក្រណាត់លាបពណ៌ មានសណ្ឋានជាសត្វតោ ឬសិង្ហ។ អ្នកសម្តែងពីរនាក់ពាក់សំលៀកបំពាក់នេះនិងរាំពេលដែលអ្នកភូមិផ្សេងៗទៀតវាយគម្របចានឆ្នាំង។ដោយសារសំលៀកបំពាក់ដ៏ចំម្លែកនោះ អ្នកភូមិអាចបន្លាចក្រុមចោរព្រៃនោះឱ្យចេញឆ្ងាយ ហើយពួកគេជឿថា ការសម្តែងរបាំម៉ុងសាយ អាចបណ្តេញភាពចង្រៃឧបទ្រព និងបន្លាចព្រលឹងបិសាចឱ្យចេញឆ្ងាយ និងនាំមកនូវសំណាងល្អ។ ដើម្បីរំលឹកព្រឹត្តិការណ៍នៃរបាំនេះ ត្រូវបានគេអនុវត្តបន្តពីជំនាន់មួយទៅជំនាន់មួយរហូតមកដល់សព្វថ្ងៃ។

រីឯ រឿងព្រេងមួយទៀតដំណាលថា កាលពីព្រេងនាយ មានសិង្ហ(ឬតោ) មួយបង្ហាញខ្លួននៅក្នុងភូមិមួយ និងបានធ្វើទុក្ខបុកម្នេញដល់អ្នកភូមិ និងសត្វស្រុក។ ពេលនោះមានគ្រូកុងហ្វូម្នាក់ បានមកដល់ភូមិនោះ និងស្ម័គ្រចិត្តចូលក្នុងភ្នំព្រៃក្រាស់ ដើម្បីប្រយុទ្ធជាមួយសិង្ហនោះ។ ការប្រយុទ្ធគ្នាមានរយៈពេល ៣ដង ប៉ុន្តែគ្រូកុងហ្វូមិនអាចយកឈ្នះឡើយ។ ដូច្នេះគ្រូនោះ បានបង្ហាត់ក្បាច់គុនកុងហ្វូដល់អ្នកភូមិមួយចំនួនឱ្យជួយសម្លាប់សិង្ហនោះ។ ប៉ុន្មានខែក្រោយមក ពួកគេឡើងភ្នំសម្លាប់សិង្ហនោះបានជោគជ័យ។ ដើម្បីអបអរដល់ជ័យជម្នះនេះ ពួកគេបានធ្វើតាមចង្វាក់ប្រយុទ្ធជាមួយសិង្ហនោះ ហើយការធ្វើត្រាប់នេះបានក្លាយជារបាំម៉ុងសាយរហូតមកដល់ពេលបច្ចុប្បន្ន។

រឿងដំណាលចុងក្រោយនៃរបាំសត្វតោនេះគឺថា អធិរាជចិន គឺព្រះអង្គ ឈីង នៃរជ្ជកាលឈីង បានសុបិនឃើញរបាំសិង្ហ ឬ របាំសត្វតោ។ បន្ទាប់មកក៏បញ្ជាដល់អង្គរក្សនៅរាជវាំង សម្តែងតាមអ្វីដែលដូចក្នុងសុបិនរបស់ព្រះអង្គ។[2]

[2] ប្រវត្តិម៉ុងសាយ តើម៉ុងសាយតំណាងអ្វី?
https://socheatorganization.wordpress.com/2013/02/08/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%9C%E1%9E%8F%E1%9F%92%E1%9E

## II. អត្ថន័យនៃរបាំម៉ុងសាយ

របាំម៉ុងសាយ ឬ របាំសត្វតោ គឺជារបាំ ដែលគេសម្តែងនៅពេលមានកម្មវិធីសប្បាយម្តងៗ ដូចជាៈការបើកសម្ពោធហាង, សម្ពោធនូវសមិទ្ធិផលថ្មីៗអ្វីមួយ, ជាកិច្ចទទួលស្វាគមន៍ភ្ញៀវកិត្តិយស និងជាពិសេសក្នុងពេលប្រារព្ធពីធីចូលឆ្នាំប្រពៃណីចិន។ របាំសត្វតោ ឬ របាំម៉ុងសាយនេះ ប្រជាជនចិនមានជំនឿថា នឹងនាំការលើករាសីជោគជ័យសំណាងល្អ និង បណ្តេញឧបទ្រពចង្រៃ ហើយនាំមកនូវលាភសំណាងសម្រាប់ឱកាសចូលឆ្នាំថ្មី។ ម្យ៉ាងទៀត របាំនេះក៏អាចធ្វើការទាក់ទាញដល់អ្នកទស្សនាជាច្រើនផងដែរ មិនថាក្មេងចាស់ ប្រុសស្រីនោះទេ តែងតែចង់ទស្សនារបាំនេះមិនដែលជិនណាយឡើយ ព្រោះភាពក្រមិចក្រមើមរបស់សត្វតោ ឬ ម៉ុងសាយនេះ មានការទាក់ទាញ។ ជាពិសេស មានឈុតឆាកលោតផ្លោះលើបង្គោលដែក ដែលធ្វើឱ្យទស្សនិកជន មានអារម្មណ៍ប្លែក និងមានការភិតភ័យជំនួសអ្នកសម្តែង។ ប៉ុន្តែរបាំម៉ុងសាយ គឺជាញឹកញាប់ត្រូវបានគេច្រឡំនឹងរបាំនាគ(Dragon Dance)។ អ្វីដែលជាការងាយស្រួលសម្គាល់ពីការរាំម៉ុងសាយ (Lion Dance) គឺថាជាទូទៅ ការរាំម៉ុងសាយត្រូវការមនុស្សតែពីរនាក់ទេ ផ្ទុយពីរបាំនាគ ដែលគេត្រូវការមនុស្សច្រើន។ ម៉្យាងការរាំម៉ុងសាយ គេមិនងាយឃើញមុខអ្នករាំទេ ព្រោះគ្របជិតដោយសម្លៀកបំពាក់មានសណ្ឋានជាសត្វតោ ខណៈដែលរបាំនាគគឺអាចមើលឃើញអ្នករាំច្បាស់ ព្រោះនាគគេគ្រាន់តែកាន់បង្គោលឈើជ្រោងគ្រវីគ្រវាត់តាមចលនាសត្វនាគប៉ុណ្ណោះ ជាហេតុធ្វើឱ្យគេអាចមើលឃើញរូបរាងមនុស្សច្បាស់។

## III. ការពិពណ៌នាអំពីរបាំសត្វតោ ឬ ម៉ុងសាយ

ដូចដែលបានលើកឡើង របាំម៉ុងសាយ ឬ របាំសត្វតោ គឺជាការសម្តែងក្បាច់រាំបែបប្រពៃណីចិន នៅក្នុងឱកាសពិសេសធំៗ ដូចជាពិធីបុណ្យចូលឆ្នាំចិន ជាដើម ដើម្បីនាំមកនូវសំណាងល្អ ព្រោះគេជឿជាក់ថាតោ ជាសត្វដ៏វិសេសវិសាល។ ម៉ុងសាយត្រូវបានគេធ្វើឡើងពី គ្រោងឬស្សី បិតដោយក្រដាស និងមានមនុស្សពីរនាក់សម្តែង ម្នាក់កាន់ក្បាល ហើយម្នាក់ទៀតកាន់កន្ទុយ និងចលនាពួកគេធ្វើទៅតាមចង្វាក់ភ្លេងស្គរ។ ចំពោះការសម្តែងគឺ ម៉ុងសាយ ឬ សត្វតោ នោះហាក់ដូចជាទើបនឹងភ្ញាក់និងស្រេកឃ្លាន ត្រូវឆ្លងកាត់ឧបសគ្គជាច្រើន (ឡើង លោត ផ្លោះបង្គោល) ដើម្បីស៊ីអាហារ ដែលមានបន្លែបៃតងនាំសំណាង ផ្លែឈើនាំសំណាង(ក្រូច) និង អាំងប៉ាវ (នាំសំណាងល្អដល់មុខរបររកស៊ី) [3] ការលោតម៉ុងសាយ ឬ របាំតោនេះមានពីរទម្រង់ធំៗ គឺ របាំសត្វតោភាគខាងជើង និង តោភាគខាងត្បូង។ ទាំងពីរទម្រង់នេះគឺធម្មតាត្រូវបានគេរកឃើញនៅក្នុងប្រទេសចិន ប៉ុន្តែនៅជុំវិញពិភពលោកជាពិសេសនៅអាស៊ីអាគ្នេយ៍ របាំសត្វតោភាគខាងត្បូងមានភាពលេចធ្លោជាង ដោយសារតែវាបានសាយភាយតាមរយៈសហគមន៍ជនជាតិដើមចិន (Chinese diaspora communities) ដែលភាគច្រើនមានប្រវត្តិដើមជាជនជាតិចិនភាគខាងត្បូង។ ការសម្តែងរបាំម៉ុងសាយនេះក៏ត្រូវបានគេឃើញមាននៅ

%8F%E1%9E%B7%E1%9E%98%E1%9F%89%E1%9E%BB%E1%9E%84%E1%9E%9F%E1%9E%B6%E1%9E%99-%E1%9E%8F%E1%9E%BE%E1%9E%98%E1%9F%89%E1%9E%BB%E1%9E%84%E1%9E%9F/

[3] ស្វែងយល់ប្រវត្តិសិល្បៈលោតម៉ុងសាយ! ម្តេចបាន ជនជាតិចិននិយមពេលចូលឆ្នាំថ្មី? https://mytvplus.com.kh/archives/15386 (accessed January 03, 2022, at 10:20 am)

ក្នុងប្រទេសជប៉ុន កូរ៉េ ទីបេ និង វៀតណាមផងដែរ។ចំពោះរូបរាងរបស់សត្វតោ ឬ ម៉ុងសាយ និងពណ៌រោមក៏មានអត្ថន័យរបស់វាផងដែរ។ ទ្រឹស្តីគ្រឿងផ្សំ ចំនួនប្រាំពណ៌ តំណាងនិមិត្តសញ្ញាទាំងប្រាំបី និង ពណ៌គឺសុទ្ធតែទាក់ទងនឹងហុងស៊ុយ ដែលជាមូលដ្ឋានសម្រាប់បកប្រែនិងពិពណ៌នារបស់តោ។ មនុស្សមួយចំនួន គេប្រហែលជាគិតថា វាគ្រាន់តែជារូបរាងតំណាងសត្វតោតែប៉ុណ្ណោះ តែការពិតម៉ុងសាយ គឺមានលក្ខណៈពិសេសខុសពីតោត្រង់ថា៖ ម៉ុងសាយមានស្នែងដ៏ស្រួចមួយពយមកមុខបន្តិចដូចជាសេះដុះស្នែង គឺជាឧបករណ៍ម៉្យាង ដែលប្រជាជនចិនជឿថាជាវត្ថុសម្រាប់ប្រយុទ្ធប្រឆាំងជាមួយនឹងបិសាចឬវិញ្ញាណអាក្រក់ៗជាដើម។ បើពិនិត្យឱ្យជិតដល់បន្តិចគេនឹងឃើញមានកញ្ចក់មួយ ដែលនៅក្រោមស្នែងស្ថិតនៅចំកណ្តាលថ្ងាសម៉ុងសាយ ដែលគេជឿជាក់ថាវាជាកញ្ចក់ទិព្វសម្រាប់ប្រឆាំងនឹងវិញ្ញាណអាក្រក់ផងដែរ។ ដូច្នេះហើយ នៅពេលដែលមានម៉ុងសាយថ្មីម្តងៗគេតែងតែធ្វើពិធីមួយដើម្បីគូយ័ន្តនៅលើកញ្ចក់នោះមុននឹងចេញទៅសម្តែង ហើយនេះគេហៅថា «ពិធីបើកភ្នែកម៉ុងសាយ» ។ ដោយសារតែ វត្ថុស័ក្តិសិទ្ធិទាំងពីរដ៏មានតម្លៃនេះហើយ ទើបធ្វើឱ្យអ្នកឡកម៉ុងសាយនិងអ្នកមានជំនឿលើម៉ុងសាយនេះគេប្រកាន់ដាច់ខាតហាមមិនឱ្យប៉ះពាល់ស្នែង ឬ កញ្ចក់នោះដោយដាច់ខាត ព្រោះគេគិតថាជាការមើលងាយនឹងមិនឱ្យតម្លៃលើវត្ថុទិព្វជាដើម។

រាល់ការសម្តែងរបាំម៉ុងសាយ ឬ របាំសត្វតោនេះគេក៏តែងតែសង្កេតឃើញមានមនុស្សពាក់មុខត្លុកកាន់ផ្លិតរាំមុខម៉ុងសាយ ដែលគេហៅថា «អ៊ុងឡៀរ» ចំពោះអ៊ុងឡៀរនេះមានរឿងមួយទៀត ដែលគេបានតំណាលតៗគ្នាថា មានសត្វតោមួយក្បាល ដែលតែងតែធ្វើបាបប្រជាជននៅក្នុងភូមិមួយក្រោយមកក៏មានព្រះសង្ឃចេះក្បាច់គុនមួយអង្គស្ម័គ្រចិត្តដើម្បីទៅបង្ក្រាបសត្វតោនោះ តែបង្ក្រាបមិនឈ្នះសោះ ហើយព្រះសង្ឃអង្គនោះក៏បានឱ្យប្រជាជនហាត់ក្បាច់គុនដើម្បីបង្ក្រាបតោ លុះបង្ក្រាបបានហើយតោនោះក៏ស្តាប់តាមបញ្ជាព្រះសង្ឃនោះ ហើយបែរជាតាមថែរក្សាអ្នកភូមិទៅវិញ។ ដូច្នេះហើយ ទើបនៅពេលគេឡកម៉ុងសាយម្តងៗ គេតែងតែឃើញមានអ្នកសម្តែង តែងខ្លួនជាមនុស្សដុះក្បាលពោះ ស្លៀកពាក់ដូចសង្ឃចិន និងពាក់របាំងមុខមនុស្សញញឹម អត់សក់កាន់ផ្លិតនៅពីមុខម៉ុងសាយ ដែលគេហៅជាភាសាទូទៅថា«អ៊ុងឡៀរ»។ ម៉ុងសាយជាសត្វនាំសំណាង ដូច្នេះនៅពេលគេឡកម្តងៗ គេតែងតែសម្តែងម៉ុងសាយឱ្យស៊ីស្លែ រួចស្តោះព្រួសចេញមកវិញ ដើម្បីឱ្យលាភសំណាង ដែលចេញពីមាត់ម៉ុងសាយអាចសាយភាយជុំវិញកន្លែងដែលម៉ុងសាយកំពុងតែឡក។ ប្រសិនបើម៉ុងសាយចូលផ្ទះ ឬ ហាងគេត្រូវសម្តែងម៉ុងសាយនោះត្រូវតែលិឍមាត់ទ្វារ ពេលចូលឬចេញពីផ្ទះហាងនោះដើម្បីឱ្យលាភសំណាងជិតជាមនូវដានជាប់មាត់ទ្វារ ដែលមនុស្សតែងតែឆ្លងកាត់ ហើយប្រជាជនចិននាំគ្នាតែងជាពាក្យស្លោកមួយថា «ចេញចូលសំណាងល្អ» ទៀតផង។ ហើយគេមិនដែលសម្តែងម៉ុងសាយដោយគ្មានឧបករណ៍ភ្លេងនោះឡើយ ផ្ទុយទៅវិញស្គរ ឆាប និង ជួង ដែលប្រគំជាមួយម៉ុងសាយសុទ្ធតែមានអត្ថន័យ និងអត្ថរសរបស់វាទាំងអស់។ ស្គរត្រូវបានគេតំណាងឱ្យចង្វាក់បេះដូង និងចរន្តនៃដំណើររបស់ម៉ុងសាយ ហើយជាភាសាមួយ ដែលបង្ហាញពីអារម្មណ៍របស់ម៉ុងសាយ នាពេលដែលវាកើតទុក្ខភ័យ សប្បាយចិត្ត និង ពុះកញ្ជ្រោល ខណៈដែលឆាប និង ជួងប្រដេញអមតាមស្គរបញ្ចេញមហិទ្ធិឫទ្ធិ

ក្នុងការបណ្ដេញគ្រោះចង្រៃទៀតផង។ ហើយមូលដ្ឋានគ្រឹះចម្បងសម្រាប់អ្នកឡកម៉ុងសាយគឺត្រូវចេះក្បាច់គុនខ្លះ ទើបអាចធ្វើការសម្ដែងរបាំម៉ុងសាយ ឬ របាំសត្វតោនេះ បានដោយសុវត្ថិភាព ពីព្រោះត្រូវហក់លោតផ្លោះ ឆ្លងពីបង្គោលមួយទៅបង្គោលមួយ។ ដូច្នេះហើយទើបកាលពីមុននៅពេលដែលមានសម្ដែងម៉ុងសាយ គេក៏មានការសម្ដែងជាក្បាច់គុនទៅជាមួយគ្នាផងដែរ។[4]


ម៉ុងសាយ ឬ សត្វតោភាគខាង


ម៉ុងសាយ ឬ សត្វតោភាគខាងត្បូង

## IV. ការជះឥទ្ធិពលរបាំម៉ុងសាយ ឬ របាំសត្វតោលើសកលលោក

ថ្វីត្បិតតែ មានប្រភពជាច្រើនបាននិយាយរៀបរាប់អំពីប្រវត្តិ "របាំម៉ុងសាយ ឬ របាំសត្វតោ" នេះច្រើនក៏ពិតមែន ប៉ុន្តែមានប្រភពមួយដែលច្បាស់ការជាងគេបំផុតនោះគឺ របាំម៉ុងសាយនេះមានដើមកំណើតមកពី ប្រទេសចិនតាំងពីសម័យបុរាណមកម្ល៉េះ។ រឿងដែលចម្លែកនោះគឺ របាំម៉ុងសាយកាលសម័យនោះមិនបានផលិតឡើងដើម្បីសម្ដែងទទួលយកលាភជ័យអ្វីនោះឡើយ។ ប៉ុន្តែគេបង្កើតវាឡើងគ្រាន់តែ ដើម្បីបំពេញចំណង់ក្មេកតែប៉ុណ្ណោះ ដោយសារតែនៅជំនាន់ដើមនៅប្រទេសចិនពុំមានសត្វតោនោះទេ។ ទើបតែរាជការ ហានទេ ដែលប្រទេសចិនចាប់ផ្ដើមមានសត្វតោប៉ុន្មានក្បាលបញ្ជូនចូលមកតាមផ្លូវសូត្រ ដែលជាផ្លូវពាណិជ្ជកម្មដ៏ល្បីរបស់ចិន។ នៅពេលនោះ ប្រជាជនចិនមានចិត្តរំភើបជាខ្លាំងព្រោះមិនធ្លាប់ឃើញសត្វប្រភេទនេះពីមុនមក ដូច្នេះហើយពួកគេក៏សង្កេតដំណើររបស់តោហើយបង្កើតបានជារបាំសត្វតោ ឬ ម៉ុងសាយនេះជាការកម្សាន្តនៅក្នុងសម័យនគរបីសាមកុក។ របាំឡកម៉ុងសាយនេះចាប់ផ្ដើមល្បីខ្លាំងទៅៗ នៅពេលដែលព្រះពុទ្ធសាសនាបានពង្រីកខ្លួនចូលដល់ភាគខាងជើង និងភាគខាងត្បូងនៃប្រទេសចិន។ នៅរាជការ ថាង របាំនេះត្រូវបានគេយកមកសម្ដែងជូនឱ្យព្រះមហាក្សត្រនៅក្នុងព្រះរាជវាំងទៀតផង។[5]

### 4.1. ការសាយភាយរបាំម៉ុងសាយនៅក្រៅប្រទេស

ត្បិតរបាំម៉ុងនេះមានភាពល្បីល្បាញក្នុងប្រទេសចិនខ្លាំង តែបើនិយាយនៅក្រៅប្រទេសវិញក៏មានភាពល្បីល្បាញផងដែរ។ ការរីកសាយភាពនៃរបាំនេះគឺតាមរយៈប្រជាជនធ្វើការចំណាកស្រុកទៅរស់នៅតាមតំបន់ទ្វីបផ្សេងៗមានដូចជា ទ្វីបអាស៊ី, ទ្វីបអឺរ៉ុប, ទ្វីបអាហ្វ្រិក, ទ្វីបអាមេរិកខាងជើង, ទ្វីបអាមេរិកខាងត្បូង, ទ្វីបអូសេអានី ជាដើម។ ហើយពួកគេ តែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំ ឬហៅម៉្យាង

[4] ម៉ុងសាយ និងជំនឿរបស់ប្រជាជនចិន http://www.sovrinmagazine.com/site/view_article?artid=867 (accessed January 03, 2022, at 3:04 pm)

[5] មើលគេឡកម៉ុងសាយរាល់ពេលចូលឆ្នាំចិន មានដឹងវាមានប្រវត្តិពីណាអត់? http://anarchak.com/article/37741 (accessed January 04,2022 at 10:00 am)

ទៀតថា ពិធីបុណ្យនាទាយរដូវ នេះតាមតំបន់ពួកគេ ហើយក៏មានការសំដែងនូវរបាំម៉ុងសាយ ឬ របាំសត្វតោ ក្នុងពេលចូលឆ្នាំថ្មីដើម្បីជាការកម្សាន្ត។ មិនត្រឹមតែសម្ដែងប៉ុណ្ណោះទេ ប្រជាជនចិនទាំងនោះក៏បានបង្កើតជាសមាគមជនជាតិចិន ដោយមានការបង្រៀនបង្ហាត់បង្ហាញអំពីការសម្ដែងរបាំនេះទៅដល់ក្មេងជំនាន់ក្រោយ ដោយមិនប្រកាន់ជាតិសាសន៍ និង បង្រៀនភាសាចិនផងដែរ។ ចំពោះការរីកសាយភាយនៃរបាំនេះភាគច្រើន គឺជារបាំម៉ុងសាយភាគខាងត្បូង ដោយសាយតែការចំណាកស្រុកភាគច្រើនជាប្រជាជនចិន ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសចិន។ ដូច្នេះហើយ ទើបគេឧស្សាហ៍ឃើញម៉ុងសាយប្រភេទភាគខាងត្បូងសម្ដែងច្រើនតាមបណ្ដាប្រទេសនានា មានដូចជា៖ សិង្ហបុរី, ឥណ្ឌូនេស៊ី, ម៉ាឡេស៊ី, ហ្វីលីពីន, ថៃ, កម្ពុជា ក៏ដូចជាប្រទេសដទៃទៀត ដែលមានប្រជាជនចិនរស់នៅដោយស្របច្បាប់ភាគច្រើន គឺប្រទេសស្ថិតនៅក្បែរសមុទ្រចិន។ ចំពោះប្រទេសនៅតំបន់អាមេរិកវិញ ក៏មានប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីជនជាតិចិននេះផងដែរ ដោយលើកយកប្រទេសកាណាដា ទោះបីប្រទេសនេះមិនមានថ្ងៃឈប់សម្រាកនាឱកាសចូលឆ្នាំចិនក្ដី។ ប៉ុន្តែប្រទេសនេះ មានប្រារព្ធពិធីបុណ្យចូលឆ្នាំចិន ហើយថែមទាំងមានប្រជាជនចិនរស់នៅទីនោះជាច្រើនបានប្រារព្ធពិធីនេះយ៉ាងទូលំទូលាយទៀតផង ព្រមទាំងប្រៃសណីយ៍នៃប្រទេសកាណាដាបានចែកចាយតែមប្រើ សម្រាប់ប្រើក្នុងឱកាសឆ្នាំថ្មី នៅតាមគេហដ្ឋាននីមួយៗ និង មានសម្ដែងរបាំម៉ុងសាយតាមបណ្ដាហាង ឬ ក្រុមហ៊ុន ដើម្បីបណ្ដេញឧបទ្រពចង្រៃទាំងពួង និងនាំមកនូវសិរីសួស្តី នាំលាភនាំជ័យទៅឱ្យម្ចាស់ហាង ឬម្ចាស់អាជីវកម្មថែមទៀត។[6]



រូបភាពរបាំម៉ុងសាយនៅបណ្ដាលប្រទេសជុំ

## 4.2. ការជ្រៀតចូលនូវរបាំម៉ុងសាយ ក្នុងប្រទេសកម្ពុជា

បើតាមរយៈកំណត់ត្រារបស់លោក ជីវ តាក្វាន់ បានបង្ហាញថា ជនជាតិចិន និងកម្ពុជាមានទំនាក់ទំនងការទូតព្រមទាំងសេដ្ឋកិច្ចជាមួយគ្នា តាំងពីសតវត្សទី៣ ឬទី៤នៃគ.សមកម្លេះ។ ចំណែកឯលោកបណ្ឌិតមីហ្សែល ត្រាណេ បានអធិប្បាយក្នុងសៀវភៅរបស់លោកថា តាមរបកគំហើញថ្មី និងភស្តុតាងមួយចំនួនដូចជាសិលាចារឹក និងរឿងព្រេងនិទានផងនោះ ជនជាតិចិនបានមានវត្តមាននៅលើទឹកដីកម្ពុជាតាំងពីមុនសតវត្សរ៍ទី១ នៃគ.ស ទៅទៀត។ ដូច្នេះមិនមែនជារឿងចម្លែកប៉ុន្មានទេចំពោះវត្តមានជនជាតិចិននិង វប្បធម៌របស់ចិន នៅលើទឹកដីកម្ពុជារបស់យើង។ ឯលោកសាស្ត្រាចារ្យ

[6] ប្រពៃណីបុណ្យចូលឆ្នាំ និងទំនៀមទំលាប់របស់ជនជាតិចិន https://kohsantepheapdaily.com.kh/article/158352.html (accessed January 05, 2022, at 1:30 Pm)

បណ្ឌិត ជៀប សុផល បានរៀបរាប់ក្នុងឯកសាររបស់លោកថា ជនជាតិចិនបានមានវត្តមាន លើទឹកដីកម្ពុជា ជាយូរយារណាស់មកហើយ ។ ជនជាតិចិនទាំងនេះមាន៥ជនជាតិ គឺចិនទៀជីវ ចិនកាតាំង ចិនហៃណាំ ឬ ហៃណាន ចិនហុកគៀន ចិនហ៊ូឌស៊ាន ឬ ចិនខិ។ តាមរយៈនេះ ពីមួយឆ្នាំទៅមួយឆ្នាំ ប្រជាពលរដ្ឋខ្មែរជាប់ខ្សែស្រឡាយចិន ឬ ខ្មែរកាត់វៀតណាម និង ជនជាតិចិនរស់នៅលើទឹកដីខ្មែរទាំងអស់ ដែលមានសមាគម ក្នុងប្រទេសកម្ពុជាតែងតែនាំគ្នាប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន ក្នុងលក្ខណៈយ៉ាងគគ្រឹកគគ្រេងបំផុត។ ក្នុងនោះដែរក៏មានវត្តមានរបាំ ដែលពេញនិយមក្នុងពេលប្រារព្ធពិធីបុណ្យចូលឆ្នាំចិននេះផងដែរ គឺ របាំឡុកម៉ុងសាយ ឬ របាំសត្វតោ ដែលគេអញ្ជើញក្រុមអ្នកសម្តែងរបាំនេះទៅសម្តែងនៅតាមផ្ទះ, ក្រុមហ៊ុនធំៗ , តាមផ្សារទំនើប និង ទីតាំងលក់ដូរផ្សេងៗ។ល។ ដើម្បីជួយដេញកម្ចាត់នូវភាពអពមង្គលឧបទ្រពចង្រៃឧត្បាតផ្សេងៗឱ្យវិនាសបាត់ទៅ ហើយលើករាសី សិរីសួស្តី សុភមង្គល និងលាភជ័យមកវិញ។ [7] ជាក់ស្តែងប្រជាជនកម្ពុជាក៏មានការចូលចិត្តទស្សនាការសម្តែងរបស់ក្រុមរបាំម៉ុងសាយ ឬ របាំសត្វតោនេះ មិនថាមនុស្សចាស់ក្មេងប្រុសស្រី គឺតែងតែចង់ឃើញរបាំនេះ ដោយសារតែមានប្រជាប្រិយភាពបែបនេះហើយទើបមានសាលាភាសាចិនមួយចំនួនបានបង្រៀនសិស្សអំពីរបាំនេះដោយមិនគិតប្រាក់ចំពោះសិស្សានុសិស្សណា ដែលមានការស្រលាញ់ចូលចិត្តរបាំនេះ ថែមពីលើនេះទៅទៀត សិស្សានុសិស្ស ដែលមានសមត្ថភាពអាចចេញទៅសំដែងលើឆាកអន្តរជាតិ និងអាចរកចំណូលពីការសម្តែងរបាំម៉ុងសាយនេះផងដែរ។



រូបភាពការបង្ហាត់ និង ការសម្តែងរបាំម៉ុងសាយដល់

[7] លំហូរជនជាតិចិន និងប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន-វៀតណាម លើទឹកដីកម្ពុជា https://www.interconrooster.com/archives/2020/01/22/37896 (accessed January 06, 2022,at 3:30 pm)

## V. សន្និដ្ឋាន

ដូចដែលបានដឹងហើយថាប្រជាជនចិន និង ប្រជាជននៅបណ្ដាប្រទេសផ្សេងៗភាគច្រើន ពួកគេបានស្គាល់នូវរបាំម៉ុងសាយ ឬ របាំសត្វតោ ហើយមានការទទួលស្គាល់នូវការសម្ដែងរបស់របាំនេះ ដោយមានភាពក្រមិចក្រមើម ស្រៀវស្រើបជំនួសអ្នកសម្ដែងម្ដងៗនៅពេលដែលការសម្ដែងលោតផ្លោះរំលងបង្គោលដែកបូកផ្សំ និង សម្លេងឧបករណ៍ប្រគុំភ្លេងរបស់របាំនេះគួរឱ្យទាក់ទាញទើបធ្វើឱ្យរបាំនេះមានភាពរស់រវើក ដក់ជាប់ក្នុងចិត្តទស្សនិកជនគ្រប់រូប។ ជាការពិតណាស់ បើនិយាយអំពីរបាំម៉ុងសាយ នាសម័យបុរាណវិញ របាំមួយនេះក៏ជារបាំដ៏ពេញនិយមមួយក្នុងការសម្ដែង និង បង្ហាញក្បាច់គុនមួយចំនួន ជូនដល់ព្រះមហាក្សត្រ ឬ អធិរាជ ដើម្បីជាការទស្សនាកម្សាន្តនាឱកាសពិធីបុណ្យធំៗក្នុងព្រះរាជវាំង នាសម័យ សាមកុក (នគរបី)។ បើនិយាយអំពីផ្នែកជំនឿសាសនាវិញ របាំនេះក៏មានជំនឿខ្លាំងលើសត្វតោរបស់របាំនេះផងដែរ ដោយគេជឿថា ជាសត្វដែលមានឥទ្ធិពលបំផុតក្នុងការដេញសភាវៈអាក្រក់ និងនាំមកនូវលាភសំណាងចូលក្នុងផ្ទះ ការជួញដូរ (ជំនួញ)សមប្រកប និង គ្រួសារមានសុភមង្គល។ ហើយជំនឿនេះក៏មានការរីកសាយភាយល្បីល្បាញតៗគ្នា ពីប្រទេសមួយទៅប្រទេសមួយ នៅក្នុងទ្វីបអាស៊ីរហូតទ្វីបផ្សេងៗតាម រយៈការធ្វើចំណាកស្រុក របស់ប្រជាជនចិនទៅតាមប្រទេសផ្សេងៗ ដោយមានការបង្កើតជាសមាគមជនជាតិចិន ឬ ទីក្រុងតូចៗ នៅក្នុងបណ្ដាប្រទេស ដែលមានប្រជាជនចិនរស់នៅ ដូចជា៖នៅតាមបណ្ដាកន្លែងជាប់នឹងសមុទ្រជាដើម។ ប្រជាជនចិនទាំងនោះតែងតែប្រារព្ធពិធីបុណ្យ ,ពិធីរៀបអាពាហ៍ពិពាហ៍, សម្ពោធក្រុមហ៊ុន ឬ អគារថ្មី ជាពិសេសក្នុងឱកាស ប្រារព្ធពិធីបុណ្យចូលឆ្នាំចិន ត្រូវតែមានការសម្ដែងរបាំម៉ុងសាយនេះជូនសារធារណៈជនទស្សនាផងដែរ ទើបធ្វើឱ្យគេស្គាល់របាំនេះច្រើន មិនតែប៉ុណ្ណោះ របាំនេះក៏មានការបង្ហាត់បង្រៀនពីគ្រូជំនាញៗ ក្នុងសហគមន៍ចិន ទៅដល់សិស្សនិស្សិត ដោយមិនមានប្រកាន់ជាតិសាសន៍ពណ៌សម្បុរនោះឡើយ។ ហើយថែមទាំងជ្រើសរើសសិស្សានុសិស្សណាដែលមានសមត្ថភាព យកទៅបណ្ដុះបណ្ដាលសម្រាប់ទៅសម្ដែងលើឆាកអន្តជាតិថែមទៀតផង។ ទើបធ្វើឱ្យរបាំនេះមានភាពល្បីល្បាញមិនថានៅតំបន់អាស៊ី អឺរ៉ុប និង អាមេរិកឡើយ។ ដោយសារតែការរីកសាយភាយនូវវប្បធម៌ជនជាតិចិនដូចនេះហើយទើបរបាំម៉ុងសាយ ឬ របាំសត្វតោនេះមានការថែរក្សាមកដល់បច្ចុប្បន្ននេះ៕



ការសម្ដែងរបាំម៉ុងសាយនាឱកាសបុណ្យចូលឆ្នាំចិន